# មេរៀនទី ៩៧៖ ព្រះជាម្ចាស់មានបន្ទូលទៅសាំយូអែល

## ១ សាំយូអែល ៣៖១-២១

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/_-42AHw6vJI

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/6AHkGo-dgNg

**គោលបំណង៖** ព្រះដឹកនាំយើង។

**ខគម្ពីរចងចាំ៖ ១ សាំយូអែល ៣៖១០** *"សូមទ្រង់មានព្រះបន្ទូលមកចុះ ដ្បិតទូលបង្គំ ជាអ្នកបំរើទ្រង់ប្រុងស្តាប់ហើយ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ខ្ញុំដើរតាមព្រះយេស៊ូវ https://youtu.be/aasilZXGorc
២. ខ្ញុំបានសម្រេចចិត្ត https://youtu.be/MR1Yv--Q4oo
៣. ព្រះបន្ទូលជាចង្កៀង https://youtu.be/fOSOZBVSb0Y

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត

**«តើអ្នកងងឹតឬ?»**



១. ឲ្យកុមារចាប់ដៃគូពីរៗនាក់។

២. ឲ្យកុមារម្នាក់ឈរនៅផ្នែកម្ខាងនៃថ្នាក់រៀន ហើយកុមារម្នាក់ទៀតឈរនៅផ្នែកម្ខាងទៀតនៃថ្នាក់រៀន។

៣. ដៃគូរម្នាក់ត្រូវដើរតួជាអ្នកពិការភ្នែក ហើយត្រូវដើរបិតភ្នែកក្នុងការស្វែករកដៃគូរបស់គេម្នាក់ទៀត។

៤. ដៃគូរដែលមិនពិការភ្នែកអាចហៅឈ្មោះដៃគូម្នាក់ទៀតបាន ដើម្បីជួយដល់ដៃគូរដែលពិការភ្នែកនោះឲ្យរកគាត់ឆាប់ឃើញ។ (គ្រូត្រូវផ្លាស់ប្តូរទីតាំងរបស់កុមារដែលមិនពិការភ្នែកនោះ ដើម្បីឲ្យកុមារដែលពិការភ្នែកនោះមានការភ័ន្តច្រឡំ។)

៥. ក្រុមណាដែលអាចស្វែងរកដៃគូរបស់ពួកគេបានមុនគេក្រុមនោះជាអ្នកឈ្នះ។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា តើវាមានសារៈសំខាន់ប៉ុនណា ក្នុងការស្វែងរកដៃគូរបស់ពួកគេ។ ក៏ដូចគ្នានេះដែរ ព្រះតែងតែផ្តល់នូវសញ្ញាអ្វីមួយ ដែលអាចជួយឲ្យយើងធ្វើការជ្រើសរើសឲ្យបានត្រឹមត្រូវនៅក្នុងជីវិតរស់នៅ។

### ៤. ការណែនាំមេរៀន

នៅពេលដែលឪពុកម្តាយឬ គ្រូរបស់អ្នកហៅឈ្មោះអ្នក ជារឿយៗអ្នកត្រូវយកចិត្តទុកដាក់ស្តាប់ ដើម្បីឲ្យអ្នកទទួលបាននូវព័ត៌មាន ឬក៏ការណែនាំដ៏សំខាន់នោះ។ ហើយជាការពិតណាស់ព្រះក៏អ៊ីចឹងដែរ។ ព្រះត្រាស់ហៅយើង ហើយមានបន្ទូលមកកាន់យើង ដើម្បីផ្តល់ការណែនាំសម្រាប់យើង។ ប៉ុន្តែ តើយើងបានស្តាប់ព្រះដែរឬទេ? តោះសូមឲ្យ យើងបានក្រឡេកទៅមើលរឿងនៅក្នុងព្រះគម្ពីរជាមួយគ្នា ពីរបៀបដែលក្មេងប្រុសម្នាក់បានឆ្លើយតបជាមួយព្រះ នៅពេលដែលព្រះមានបន្ទូលមកកាន់គាត់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

សាំយូអែលបានបម្រើព្រះតាំងតែពីគាត់កើតមកម្លេះ។ គាត់បានបម្រើព្រះជាមួយនឹងសង្ឃអេលីនៅក្នុងព្រះវិហារមួយ។ នៅយប់មួយ នៅពេលដែលមនុស្សគ្រប់គ្នាបានចូលសម្រាកអស់នោះ ព្រះទាក់ទាញចំណាប់អារម្មណ៍របស់សាំយូអែល ដោយការហៅឈ្មោះរបស់គាត់។ សាំយូអែលគ្រាន់តែជាក្មេងតូចម្នាក់ដូចអ្នកតែប៉ុណ្ណោះ! ដូច្នេះគាត់គិតថា សង្ឃអេលីទេដែលជាអ្នកហៅឈ្មោះគាត់នោះ។ ការដែលព្រះហៅឈ្មោះគាត់ចំនួន៣ដងដំបូង សាំយូអែលបានរត់ទៅឯសង្ឃអេលី ហើយសួរថា លោកមានការអី។ អេលីមានការងឿងឆ្ងល់ជាខ្លាំង ព្រោះគាត់មិនបានហៅសាំយូអែលនោះទេ។ ប៉ុន្តែលើកទី៣ អេលីបានពន្យល់ប្រាប់សាំយូអែលថា គឺជាព្រះទេ ដែលជាអ្នកចង់និយាយទៅកាន់សាំយូអែលឯងនោះ។

នៅពេលដែលសាំយូអែលបានដឹងថា គឺព្រះចង់មានបន្ទូលមកកាន់គាត់នោះ សាំយូអែលបានបើកចំហចិត្តនិងយាងព្រះវត្តមានរបស់ព្រះ ដើម្បីឲ្យព្រះបានមានបន្ទូលមកកាន់គាត់ ហើយគាត់បានស្តាប់យ៉ាងយកចិត្តទុកដាក់។ ព្រះបានប្រាប់ពីផែនការរបស់ទ្រង់ចំពោះ សង្ឃអេលី។

ចាប់តាំងពីយប់នោះមកព្រះតែងតែនិយាយប្រាប់សាំយូអែលពីផែនការរបស់ទ្រង់។ នៅពេលដែល សាំយូអែល តែងតែស្តាប់ពីការនាំផ្លូវរបស់ព្រះ នោះគាត់ក៏កាន់តែមានភាពងាយស្រួលក្នុងការស្តាប់ ព្រះសូរសៀងរបស់ព្រះ។ ហើយមនុស្សម្នាផ្សេងទៀត ដែលជាជនជាតិអ៊ីស្រាអែលក៏បានស្តាប់ពីការបង្ហាញផ្លូវរបស់ព្រះតាមរយៈសាំយូអែលដែរ។

យើងត្រូវតែត្រៀមខ្លួនជានិច្ចក្នុងការស្តាប់បង្គាប់ព្រះ និងដើរតាមផែនការរបស់ទ្រង់ពីព្រោះថា ព្រះមានបន្ទូលមកកាន់មនុស្សគ្រប់គ្នា បើទោះបីជាយើងនៅក្មេងដូចជាសាំយូអែលក៏ដោយ។ នៅពេលដែលយើងអាចស្តាប់ឮពីព្រះបន្ទូលរបស់ព្រះ យើងក៏អាចដឹងពីការដឹកនាំរបស់ព្រះ នៅពេលដែលមានរឿងអាក្រក់កើតឡើងនៅក្នុងជីវិតរស់នៅរបស់យើងដូចគ្នា។

យើងដឹងថាព្រះជាម្ចាស់មានចិត្តសប្បុរស ពោរពេញទៅដោយសេចក្តីស្រលាញ់ និងប្រព្រឹត្តតែអំពើល្អ។ ព្រះដឹកនាំយើងឲ្យដូចជារូបអង្គទ្រង់ ហើយធ្វើតែអ្វីដែលត្រឹមត្រូវ។ ប្រសិនបើនរណាម្នាក់ប្រាប់ឲ្យអ្នកធ្វើនូវរឿងអាក្រក់ នោះយើងមិនត្រូវធ្វើតាមគេនោះឡើយ ចូលកុំខ្វល់ពីវាឲ្យសោះ។ សូមឲ្យយើងស្តាប់តាមការដឹកនាំរបស់ព្រះ ពីព្រោះថា ព្រះតែងតែមានផែនការដ៏ល្អបំផុតសម្រាប់យើង!

## ៦. សំនួរពិភាក្សា

១. តើព្រះមានបន្ទូលទៅកាន់សាំយូអែលនៅពេលណា? *(នៅពេលយប់ជ្រៅ)*

២.តើមានអ្វីខ្លះកើតឡើង នៅពេលដែលសាំយូអែលស្តាប់តាមព្រះកាន់តែច្រើន ?

*(ធ្វើឲ្យគាត់មានភាព ងាយស្រួលក្នុងការញែកឲ្យដាច់មួយណាជាសម្លេងរបស់ព្រះ)*

៣. តើព្រះមានបន្ទូលទៅកាន់នរណាខ្លះ? *(មនុស្សគ្រប់គ្នា)*

៤.តើអ្នកដឹងដោយរបៀបណាថានេះជាការដឹកនាំដែលបានមកពីព្រះ?
*(ព្រះដឹកនាំយើងឲ្យដូចជារូបអង្គ ទ្រង់ ហើយធ្វើនូវអ្វីដែលត្រឹមត្រូវ)*

## ៧. ល្បែងកំសាន្ត «បាល់ស្គាល់ឈ្មោះ»

សម្ភារៈដែលត្រូវការ៖ កូនបាល់

១. ឲ្យកុមារឈរ ឬអង្គុយជារង្វង់



២. **ជំហានទី១** ឲ្យកុមារបោះបាល់ទៅកុមារណាម្នាក់ដោយនិយាយ ឈ្មោះខ្លួនឯង។ បន្តលេងល្បែងនេះរហូតដល់កុមារគ្រប់គ្នាចាំ ឈ្មោះគ្នាអស់។

៣. **ជំហានទី២** ឲ្យកុមារបោះបាល់ទៅកុមារណាម្នាក់ ដោយ និយាយ ឈ្មោះខ្លួនឯង ហើយហៅឈ្មោះអ្នក ដែលយើងត្រូវបោះបាល់ឲ្យនោះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ព្រះស្គាល់ឈ្មោះរបស់យើងទាំងអស់គ្នា។ នៅពេលដែលព្រះហៅឈ្មោះយើងនោះ យើងត្រូវតែស្តាប់ព្រះដោយយកចិត្តទុកដាក់ដូចជា សាំយូអែលអ៊ីចឹង។

## ៨. ខគម្ពីរចងចាំ

**១ សាំយូអែល ៣:១០** *"សូមទ្រង់មានព្រះបន្ទូលមកចុះ ដ្បិតទូលបង្គំ ជាអ្នកបំរើទ្រង់ ប្រុងស្តាប់ហើយ។"*

## ៩. ហត្ថកម្ម «ខ្ញុំស្តាប់តាមព្រះ»

សម្ភារៈដែលត្រូវការ៖ បោះពុម្ពរូប ត្រចៀក សម្រាប់កុមារគ្រប់គ្នា (ទំព័រខាងក្រោម) ក្រដាស កូល័រទៀន ការបិត និងកន្ត្រៃ



១. ផាត់ពណ៌រូបត្រចៀកហើយកាត់វាចេញមក។

២. ធ្វើរង្វង់មូលមួយពីក្រដាសឲ្យប៉ុនក្បាលរបស់កុមារ ហើយ សរសេរពាក្យថា "ខ្ញុំស្តាប់តាមព្រះ" ។

៣. បិតត្រចៀកនៅចហៀងសងខាងរង្វង់។

៤. ឲ្យកុមារពាក់នៅលើក្បាលពួកគេ ហើយឲ្យកុមារទាំងអស់និយាយថា "ខ្ញុំស្តាប់តាមព្រះ!" ។

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូៈ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
នៅក្នុងទំនាក់ទំនងរបស់យើងជាមួយព្រះយេស៊ូវ ពេលខ្លះព្រះបានមានបន្ទូលមកកាន់ យើងតាមរយៈព្រះគម្ពីរ ឬក៏កូនរបស់ព្រះអង្គណាម្នាក់។ នៅពេលដែលទ្រង់ធ្វើការទាំងអស់នេះ ទ្រង់ចង់ឲ្យយើងដើរតាម និងស្តាប់បង្គាប់ទ្រង់។ សូមឲ្យយើងបានអានព្រះគម្ពីរ **១ សាំយាំអែល ៣:១៣**, **១៩-២០** សារឡើងវិញ។ តើវាមានន័យដូចម្តេចនៅពេលដែលយើងពិតជាស្តាប់តាមព្រះ? បើសិនជាប្រៀបធៀបជាមួយសាំយូអែល តើអ្នកស្តាប់បន្ទូលរបស់ព្រះដោយរបៀបណា? តើអ្វីដែលព្រះនឹងនាំអ្នកឲ្យធ្វើ? ការធ្វើតាមការណែនាំរបស់ព្រះដោយស្មោះត្រង់ក្នុងជីវិតរបស់យើង នឹងនាំយើងទៅរកអ្វីដែលល្អបំផុតដែលព្រះមានសម្រាប់យើង។ សូមស្តាប់សំឡេងរបស់ព្រះនៅថ្ងៃនេះ។

# ខ្ញុំស្តាប់តាមព្រះ!



